**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៣៥ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ជំរឿនសមាគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ÷

- ទទួលបាននូវព័ត៌មានសេដ្ឋកិច្ចស្តីពីសហគ្រាសគ្រប់វិស័យ សម្រាប់បម្រើអ្នកប្រើប្រាស់នានា
- ធ្វើជាទិន្នន័យមូលដ្ឋាន សម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងនានា ដើម្បីជំរុញកិច្ចអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពប្រជាជន ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត លើគ្រប់អង្គភាពសេដ្ឋកិច្ចទាំងអស់ ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែអង្គភាពកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ÷

- សហគ្រាស សំដៅដល់អង្គភាពអាជីវកម្ម ឬផ្នែកមួយនៃអង្គភាពអាជីវកម្ម ដែលមានទីតាំងមួយជាក់លាក់ ហើយមានសកម្មភាពផលិតកម្មតែមួយ ឬមានសកម្មភាពផលិតកម្មសំខាន់ ដែលបង្កើតបានតម្លៃបន្ថែមមួយផ្នែកធំ
- ជំរឿនសហគ្រាស សំដៅដល់ជំរឿនផ្នែកសេដ្ឋកិច្ច ដែលអនុវត្តទៅលើអង្គភាពសេដ្ឋកិច្ច មានជាអាទិ៍ សហគ្រាសគ្រប់ប្រភេទ រោងចក្រ សហគ្រាសរដ្ឋ ឯកជន សិប្បកម្ម អាជីវកម្ម លក់ដុំ លក់រាយ និងសេវាកម្ម ផ្សេងៗ ។

## ជំពូកទី២
## កាលបរិច្ឆេទ

**មាត្រា៥.-**

កាលបរិច្ឆេទជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា កំណត់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ ។

## ជំពូកទី៣
## យន្តការ និងនីតិវិធី

**មាត្រា៦.-**

បង្កើតគណៈកម្មាធិការជាតិជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១ ដែលមានសមាសភាព

ដូចខាងក្រោម ÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| - រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| - អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | សមាជិក |
| - ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | សមាជិក |
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | លេខាធិការ ។ |

**មាត្រា៧.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ មានគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស គណៈកម្មាធិការឃោសនាជំរឿនសហគ្រាស និងគណៈកម្មាធិការជំរឿនសហគ្រាសរាជធានី ខេត្ត ដែលកំណត់ដោយសេចក្តីសម្រេច ។

**មាត្រា៨.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១ មានភារកិច្ច ÷

ក- ណែនាំ និងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនសហគ្រាស ។

ខ- រៀបចំ និងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស និងគណៈកម្មាធិការឃោសនាជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅក្រសួងផែនការ និងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការជំរឿនសហគ្រាស ។

គ- រៀបចំ និងបង្កើតគណៈកម្មាធិការជំរឿនសហគ្រាស រាជធានី ខេត្ត ។

ឃ- ចាត់តាំងមន្ត្រីឱ្យចូលរួមជំរឿនសហគ្រាស តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស ។

ង- ប្រជុំការងារយ៉ាងតិច ៦ ( ប្រាំមួយ ) ខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន ។

ច- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅ និងលទ្ធផលនៃជំរឿនសហគ្រាស ។

**មាត្រា៩.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មាធិការឃោសនាជំរឿនសហគ្រាស មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មាធិការជំរឿនសហគ្រាសរាជធានី ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់រាជធានី ខេត្ត ។

**មាត្រា១០.-**

ជំរឿនសហគ្រាស ត្រូវមានដំណាក់កាលដូចតទៅ ÷

១- កិច្ចប្រតិបត្តិការដំបូងរបស់ការជំរឿនមាន ÷

- ការរៀបចំផែនទី
- ការរាប់ និងធ្វើបញ្ជីអង្គភាពសេដ្ឋកិច្ច
- ការធ្វើអង្កេត និងជំរឿនសាកល្បង ។

២- ការធ្វើសម្ភាសអង្គភាពសេដ្ឋកិច្ចសម្រាប់ការជំរឿន ។

៣- កិច្ចប្រតិបត្តិការចុងក្រោយរបស់ការជំរឿនមាន ÷

- ការធ្វើអង្កេតសម្រាប់ការវាយតម្លៃលើការជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀតក្នុងករណីចាំបាច់ ។

**មាត្រា១១.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអគ្គនាយកជំរឿនសហគ្រាស និងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ទីរផែនការរាជធានី ខេត្ត ជួយរាល់ការងារក្នុងការជំរឿន ។

**មាត្រា១២.-**

មន្ត្រីបំពេញការងារជំរឿនរួមមាន អ្នកត្រួតពិនិត្យការសម្ភាស អ្នកសម្ភាសស្រង់យកព័ត៌មាន និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការជំរឿន ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់អគ្គនាយក

ជំរឿនសហគ្រាស ។ ការចាត់ចែងនេះអនុវត្តបានតែក្នុងអំឡុងពេលជំរឿនតែប៉ុណ្ណោះ ។

**មាត្រា១៣.-**

រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងប្រជាពលរដ្ឋ ដើម្បីសហការជួយធ្វើកិច្ចការជំរឿនសហគ្រាស ។

**មាត្រា១៤.-**

ម្ចាស់អង្គភាពសេដ្ឋកិច្ច ត្រូវសហការ និងអនុញ្ញាតឱ្យមន្ត្រីបំពេញការងារជំរឿន ដែលបង្ហាញលិខិតបេសកកម្មផ្លូវការ បានចូលក្នុងអង្គភាពសេដ្ឋកិច្ច លំនៅឋាន ឬទីកន្លែងរបស់ខ្លួន ក្នុងគោលដៅនៃការជំរឿន និងអនុញ្ញាតឱ្យមន្ត្រីទាំងនោះ អាចលាបពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសម្គាល់នៅតាមកន្លែងចាំបាច់ សម្រាប់បម្រើដល់ការងារជំរឿនសហគ្រាស ។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងផែនការ អាចប្រកាសចាត់តាំងអ្នកគ្រប់គ្រងជំរឿនសហគ្រាស តាមទីកន្លែងដែលមានលក្ខណៈពិសេសដូចខាងក្រោម÷

ក- អ្នកគ្រប់គ្រងសហគ្រាសសាធារណៈ និងឯកជន ។

ខ- អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសម្រាកកាយ ។

គ- អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម ។

ឃ- អ្នកគ្រប់គ្រងស្ថានីយ៍រថភ្លើង ព្រលានយន្តហោះ ចំណតរថយន្ត និងកំពង់ផែ ។

ង- នាយកមន្ទីរពេទ្យ ។

ច- អ្នកគ្រប់គ្រងអង្គភាពសេដ្ឋកិច្ចផ្សេងៗទៀតដែលចាំបាច់ ។

**មាត្រា១៦.-**

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬសំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា១៧.-**

ជំរឿនសហគ្រាសមានប្រភពធនធានដូចតទៅ ÷

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា

ប្រភពធនធានផ្សេងៗ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងសមាជិកគណៈកម្មាធិការជាតិ ដូចក្នុងមាត្រា ៦ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*